YUNNAN DAILY PRESS GROUP
No.135

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 25 លេខ 7509 ថ្ងៃសុក្រ ទី15 ខែធ្នូ ឆ្នាំ 2017

## រដ្ឋាភិបាលថៃអនុម័តរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន វិស្វកម្មដំណាក់កាលទី១នៃគម្រោងសាងសង់ផ្លូវដែកថៃ-ចិន

***ដោយៈយ៉ាង ចូវ (ស៊ីនហួចិន)***

កាលពីថ្ងៃទី ៤ ខែធ្នូ វេបសាយរដ្ឋាភិបាលថៃ បានប្រកាសព័ត៌មានជាសាធារណៈថា រដ្ឋាភិបាលថៃបានអនុម័តរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានវិស្វកម្មដំណាក់កាលទី១នៃគម្រោងសាងសង់ផ្លូវដែកថៃ-ចិន ។

ស្ថាប័នទទួលខុសត្រូវចំពោះការវាយតម្លៃផលប៉ះពាល់បរិស្ថាននៃក្រសួងធនធានធម្មជាតិ និងបរិស្ថានថៃ បានប្រកាសព័ត៌មានតាមវេបសាយថា នៅថ្ងៃទី៣០ ខែវិច្ឆិកា គណៈកម្មាធិការវាយតម្លៃផលប៉ះពាល់បរិស្ថានជាតិថៃ បានអនុម័តរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានគម្រោងសាងសង់ផ្លូវដែកកំណាត់ទី២ ផាជី-ណាខនរាជសីម៉ា (Phachi-Nakhon Ratchasima) នៃវិស្វកម្មដំណាក់កាលទី១ ផ្លូវដែកថៃ-ចិន ។

គួរបញ្ជាក់ថា មុននឹងប្រកាសព័ត៌មាននេះ រដ្ឋាភិបាលថៃបានអនុម័តរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានគម្រោងសាងសង់ផ្លូវដែកកំណាត់ទី១ (បាងកក-ផាជី)នៃវិស្វកម្មដំណាក់កាលទី១ ផ្លូវដែកថៃ-ចិន ។ សេចក្ដីប្រកាសរបស់រដ្ឋាភិបាលថៃបានបង្ហាញឱ្យឃើញថា របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានវិស្វកម្មដំណាក់កាលទី១ នៃគម្រោងសាងសង់ផ្លូវដែកថៃ-ចិន បានទទួលនូវការអនុម័តទាំងស្រុងពីរដ្ឋាភិបាលថៃ ។

នៅថ្ងៃទី ៤ ខែធ្នូ លោក អាខុម ពេមពិតតាយ៉ាផៃស៊ិត រដ្ឋមន្ត្រីក្រសួងគមនាគមន៍ថៃ បានថ្លែងក្នុងសន្និសីទសារព័ត៌មានថា ក្រោយពីអនុម័តរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានគម្រោងសាងសង់ផ្លូវដែកនេះនឹងបើកការដ្ឋានសាងសង់នៅពាក់កណ្ដាលទី ២ នៃខែធ្នូ ។ នៅថ្ងៃទី ២៤ ខែវិច្ឆិកា លោកបានទម្លាយដំណឹងក្នុងកិច្ចប្រជុំលើកទី២២ នៃគណៈកម្មាធិការសហប្រតិបត្តិការគម្រោងផ្លូវដែកថៃ-ចិនថា ប្រទេសទាំងពីរបានចាប់ផ្ដើមពិគ្រោះពិភាក្សាអំពីវិស្វកម្មដំណាក់កាលទី ២ និងគម្រោងតភ្ជាប់ផ្លូវដែកថៃ-ចិន ទៅនឹងផ្លូវដែកចិន-ឡាវ ។

ផ្លូវដែកថៃ-ចិន ជាខ្សែរថភ្លើងល្បឿនលឿនស្ដង់ដារទី ១ របស់ប្រទេសថៃ ។ វិស្វកម្មដំណាក់កាលទី ១ មានប្រវែងសរុប ២៥៣ គីឡូម៉ែត្រ ហើយរថភ្លើងអាចធ្វើដំណើរក្នុងល្បឿន ២៥០ គីឡូម៉ែត្រ/ម៉ោង ចំណែកវិស្វកម្មដំណាក់កាលទី២គឺបន្តសាងសង់ផ្លូវដែកនេះរហូតទៅដល់ខេត្តណងខៃ ដែលនៅជាប់នឹងរដ្ឋធានីវៀងចន្ទន៍នៃប្រទេសឡាវហើយនឹងតភ្ជាប់ផ្លូវដែកនេះទៅនឹងផ្លូវដែកម៉ុកទីង-វៀងចន្ទន៍ ដែលជាផ្នែកមួយនៃផ្លូវដែកចិន-ឡាវ ។ គម្រោងនេះនឹងអាចលើកតម្កើងតួនាទីរបស់ប្រទេសថៃក្នុងប្រព័ន្ធគមនាគមន៍នៃឧបទ្វីបឥណ្ឌូចិនហើយនឹងចាក់បញ្ចូលកម្លាំងរស់រវើកថ្មីសម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចថៃ និងផ្ដល់ផលប្រយោជន៍ជាក់ស្ដែងដល់បណ្ដាប្រទេសពាក់ព័ន្ធដែលស្ថិតនៅតាមបណ្ដោយខ្សែរថភ្លើងនេះ៕

## ការប្រកួតបាល់ទាត់អន្តរជាតិ "ខេត្តយូនណាន ដ៏ចម្រុះពណ៌ៈខ្សែក្រវាត់ និងផ្លូវ"



*ការប្រកួតបាល់ទាត់អន្តរជាតិ "ខេត្តយូនណានដ៏ចម្រុះពណ៌ៈខ្សែក្រវាត់ និងផ្លូវ" ទាក់ទាញកីឡាករ១២ក្រុមមកពីប្រទេសផ្សេងគ្នា (រូបថតដោយ Feng Yongsheng )*

***ដោយ ៈយូ យ៉ានយ៉ាន (ស៊ីនហួចិន)***

ពេលថ្មីៗនេះ ការប្រកួតបាល់ទាត់អន្តរជាតិ "ខេត្តយូនណានដ៏ចម្រុះពណ៌ៈ ខ្សែក្រវាត់និងផ្លូវ" ឆ្នាំ២០១៧ បានបើកការប្រកួតនៅក្រុងម៉ាងស៊ឺ-មណ្ឌលស្វយ័តជនជាតិតៃនិងជនជាតិជីងភ្ល តឺហុង ខេត្តយូនណាន ។ ក្រុមបាល់ទាត់ចំនួន១២ក្រុម ដែលមកពីប្រទេសចំនួន៩ បានចូលរួមក្នុងការប្រកួតដែលមានរយៈពេល១០ថ្ងៃនេះ ។

ការប្រកួតបាល់ទាត់អន្តរជាតិ "ខេត្តយូនណាន ដ៏ចម្រុះពណ៌ៈខ្សែក្រវាត់និងផ្លូវ" ត្រូវបានរៀបចំជាលើកដំបូងនៅឆ្នាំ ២០១៣ ។ ពេលដំបូងការប្រកួតនេះមានឈ្មោះថា "ការប្រកួតបាល់ទាត់អន្តរជាតិយូនណាន-អាស៊ាន" ។

ឆ្នាំនេះ ក្រុមបាល់ទាត់ដែលមកពីប្រទេសចិន ក្រូអាស៊ី កម្ពុជា ហ្វីលីពីន ឡាវ ម៉ាឡេស៊ី ថៃ ទីម័រខាងកើត និង វៀតណាម បានចុះឈ្មោះ និងចូលរួមក្នុងការប្រកួតនេះ ៕

## កុកក្បាលខ្មៅ១.៤២២ក្បាលឆ្លងរដូវរងានៅតំបន់តាសានប៉ាវខេត្តយូនណាន

***ដោយៈចាវ កៃយ៉ាន (វេបសាយស៊ីនហួចិន)***

តំបន់អភិរក្សធម្មជាតិតាសានប៉ាវ ខេត្តយូនណាន ជាតំបន់ការពារសត្វកុកក្បាលខ្មៅថ្នាក់ជាតិដ៏សំខាន់របស់ប្រទេសចិន។តាមទិន្នន័យតាមដាននិងសិក្សាស្រាវជ្រាវពីមន្ទីរគ្រប់គ្រងតំបន់អភិរក្សធម្មជាតិនេះបានឱ្យដឹងថា គិតមកដល់ពេលនេះ ចំនួនសត្វកុកក្បាលខ្មៅដែលហើរទៅឆ្លងរដូវរងានៅតំបន់តាសានប៉ាវ បានកើនឡើងដល់ ១.៤២២ ក្បាល ។



*តំបន់អភិរក្សធម្មជាតិតាសាន ប៉ាវខេត្តយូនណានជាតំបន់ការពារសត្វកុកក្បាលខ្មៅថ្នាក់ជាតិដ៏សំខាន់ របស់ប្រទេសចិន។ នេះគឺជារូបភាព នារីនៅក្នុងមូលដ្ឋានមួយរូបកំពុងតែផ្តល់អាហារដល់សត្វកុកក្បាលខ្មៅនេះ (រូបថត ដោយ Zhou Can )*

សត្វកុកក្បាលខ្មៅជាសត្វស្លាបកម្រឃើញពិសេសរបស់ប្រទេសចិន ដែលបានត្រូវគេហៅថា "សត្វស្លាបដូចខ្លាឃ្មុំផាន់ដា" ។ កុកក្បាលខ្មៅជាប្រភេទសត្វកុកតែមួយគត់ ដែលរស់នៅលើទីខ្ពស់ជាប់រហូត ក្នុងចំណោមសត្វកុកទាំង១៥ប្រភេទលើពិភពលោក ហើយក៏ជាសត្វទទួលការការពារថ្នាក់ជាតិលេខ១ ក្នុងប្រទេសចិន ។ សព្វថ្ងៃនៅលើពិភពលោកមានសត្វកុកក្បាលខ្មៅប្រមាណតែ១១ពាន់ក្បាល ក្នុងនោះមាន៩៦ភាគរយរស់នៅក្នុងប្រទេសចិន។

លោក សួន យ៉ុង អនុប្រធានមន្ទីរគ្រប់គ្រងតំបន់អភិរក្សធម្មជាតិតាសានប៉ាវបានបញ្ជាក់ថា តាមលទ្ធផលនៃការងារតាមដាននិងសិក្សាស្រាវជ្រាវបានឱ្យដឹងថា នៅឆ្នាំ២០១៦ សត្វកុកក្បាលខ្មៅមកឆ្លងរដូវនៅតំបន់តាសានប៉ាវមានចំនួន១.៣៤៣ក្បាល ចំណែកឯឆ្នាំនេះបានកើនឡើង៧៩ក្បាល ។ និយាយជារួម ពេលដំបូងដែលបង្កើតតំបន់អភិរក្សធម្មជាតិនេះ មានសត្វកុកក្បាលខ្មៅតែជាង៣០០ក្បាល តែឆ្នាំនេះវាបានកើនឡើងដល់១.៤២២ក្បាល ។ កំណើននៃចំនួនកុកក្បាលខ្មៅដែលមកឆ្លងរដូវរងានៅតំបន់អភិរក្សធម្មជាតិតាសានប៉ាវបានបង្ហាញឱ្យឃើញថា ប្រព័ន្ធអេកូ-ធម្មជាតិនៃតំបន់អភិរក្សធម្មជាតិនេះកាន់តែមានភាពល្អប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។ លោកបន្តទៀតថា តំបន់អភិរក្សធម្មជាតិនេះស្ថិតនៅក្នុងឃុំតាសានប៉ាវ ក្រុងសាវធុង ខេត្តយូនណាន ហើយជាទីឆ្លងកាត់និងកន្លែងឆ្លងរដូវរងាដ៏សំខាន់មួយសម្រាប់សត្វកុកក្បាលខ្មៅ ។

ម៉្យាងទៀត តាំងពីដើមឆ្នាំនេះមក មន្ទីរគ្រប់គ្រងតំបន់អភិរក្សធម្មជាតិតាសានប៉ាវបានរៀបចំឱ្យដាំស្រូវ និងដំឡូងបារាំងទំហំជាង៣ហិកតា នៅជុំវិញតំបន់រស់នៅរបស់សត្វកុកក្បាលខ្មៅ ដោយមិនដែលប្រមូលផលសោះដើម្បីផ្ដល់ដល់សត្វកុកក្បាលខ្មៅនូវចំណីគ្រប់គ្រាន់ ៕

## មជ្ឈមណ្ឌលសហប្រតិបត្តិការបរិស្ថានទន្លេឡានឆាង-មេគង្គ

***ដោយ កាវ ជីង***

ពេលថ្មីៗនេះ មជ្ឈមណ្ឌលសហប្រតិបត្តិការបរិស្ថានទន្លេឡានឆាង-មេគង្គបានត្រូវបង្កើតជាផ្លូវការនៅក្រុងប៉េកាំងនៃប្រទេសចិន។មជ្ឈមណ្ឌលនេះនឹងរួមចំណែកក្នុងការពង្រឹងកិច្ច សហប្រតិបត្តិការលើវិស័យថែរក្សាការពារអេកូ-បរិស្ថាននៃប្រទេសទាំង៦តាមបណ្ដោយទន្លេឡានឆាង-មេគង្គ និងជំរុញការអភិវឌ្ឍន៍ដោយ ចីរភាព ។

លោកហួង យូនឈីវ អនុរដ្ឋមន្ត្រីក្រសួងការពារបរិស្ថានចិន មានប្រសាសន៍ថា បន្ទាប់ពីបង្កើតមជ្ឈមណ្ឌលសហប្រតិបត្តិការបរិស្ថានទន្លេឡានឆាង-មេគង្គនេះ ប្រទេសទន្លេឡានឆាង-មេគង្គនឹងរួមគ្នាកំណត់ផែនការសហប្រតិបត្តិការឱ្យបានកាន់តែល្អប្រសើរ ហើយចូលរួមយ៉ាងសកម្មក្នុងការកំណត់យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការការពារបរិស្ថានទន្លេឡានឆាង-មេគង្គបង្កើនការផ្លាស់ប្ដូរនិងការសន្ទនាអំពីគោលនយោបាយគ្រប់គ្រងបរិស្ថានក្នុងតំបន់ជំរុញការអនុវត្តគម្រោងជាក់ស្ដែង ជាពិសេសជំរុញការអនុវត្តគម្រោងសំខាន់តាម "ផែនការឡានឆាង-មេគង្គបៃតង" ដោយផ្ដោតសំខាន់ទៅលើវិស័យសហប្រតិបត្តិការអាទិភាព ដើម្បីបង្កើតជារូបភាពសហប្រតិបត្តិការថ្មីក្នុងតំបន់ និងរួមចំណែកដោយគ្រប់ជ្រុងជ្រោយក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងតំបន់ ៕

## សាលាទ័ពជើងគោកខេត្តយូនណានជាប់ឈ្មោះជាបេតិកភណ្ឌសំណង់ប្រទេសចិនសតវត្សរ៍ទី២០



*អគារនៃសាលាទ័ពជើងគោក ខេត្តយូនណាន ដែលបានជាប់ឈ្មោះជាសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រជាង១០០ ឆ្នាំ (រូបថត ដោយ elak Yang Zheng )*

ពេលថ្មីៗនេះ សមាគមសិក្សាស្រាវជ្រាវវត្ថុបុរាណចិន និងសមាគមសិក្សាស្រាវជ្រាវសំណង់ចិនបានរួមគ្នាប្រកាសនូវបញ្ជីឈ្មោះបេតិកភណ្ឌសំណង់ប្រទេសចិនសតវត្សរ៍ទី២០ ក្រុមទី២ ។ សាលាទ័ពជើងគោកខេត្តយូនណានបានត្រូវដាក់បញ្ចូលក្នុងបញ្ជីឈ្មោះនេះ ។

សាលាទ័ពជើងគោកខេត្តយូនណាន មានទីតាំងស្ថិតនៅជាប់នឹងបឹងឈួយហ៊្វូក្នុងទីក្រុងគុនមីង។ សាលានេះបើកការដ្ឋានសាងសង់នៅឆ្នាំ ១៩០៧ ហើយបញ្ចប់ការសាងសង់ជាស្ថាពរនៅឆ្នាំ១៩០៩ ។ ពេលដំបូងសាលានេះមានផ្ទៃក្រឡាសរុបជាង៧ម៉ឺនម៉ែត្រការ៉េ ដោយចែកចេញជាពីរផ្នែក ពោលគឺផ្នែកខាងត្បូងជាកន្លែងសម្រាប់ហ្វឹកហាត់ ឯផ្នែកខាងជើងមានអគារតូចធំជាច្រើន ។ សាលានេះមានទ្រង់ទ្រាយធំ និងមានភាពអស្ចារ្យ ដោយធ្លាប់ជាប់ចំណាត់ថ្នាក់លេខ១ ក្នុងចំណោមសាលាយោធាផ្សេងៗក្នុងប្រទេសចិននៅសម័យនោះ ។ ប៉ុន្តែបច្ចុប្បន្ននេះ សាលានេះសល់តែអគារសំខាន់មួយចំនួន ដែលមានផ្ទៃក្រឡាជិត៣ម៉ឺនម៉ែត្រការ៉េ រួមមានអគារសិក្សាសំខាន់ សាលប្រជុំធំ និងឃ្លាំងស្តុកអាវុធ ៕

**(កាសែតយូនណាន ដេលី)**

## ពិធីផ្សព្វផ្សាយកម្មវិធី "រោងល្ខោន-ចិន" ប្រារព្ធនៅរាជធានីភ្នំពេញ

ពេលថ្មីៗនេះ ពិធីផ្សព្វផ្សាយកម្មវិធី "រោងល្ខោនចិន" ដែលរៀបចំដោយវិទ្យុប្រជាជនចិនខេត្តក្វាងស៊ីនិងស្ថានីយទូរទស្សន៍ជាតិកម្ពុជាបានរៀបចំនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ។ ពិធីផ្សព្វផ្សាយនេះបានទទួលការចាប់អារម្មណ៍ពីជនជាតិខ្មែរជាច្រើន ដែលចូលចិត្តមើលខ្សែភាពយន្តចិន ។

អ្នកដាក់សំឡេងឱ្យតួឯកបុរសនិងស្រ្តីនៃភាពយន្តរឿងភាគចិន "សួស្ដីឈីវអាន" បានចូលរួម និងបង្ហាញការដាក់សំឡេងដោយផ្ទាល់ក្នុងពិធីផ្សព្វផ្សាយនេះ ។ ពួកគេក៏បានចែករំលែកគ្នាជាមួយទស្សនិកជនខ្មែរអំពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួន និងបានទទួលនូវការស្វាគមន៍យ៉ាងរាក់ទាក់កក់ក្ដៅ ។ ជាពិសេស ភាគីរៀបចំពិធីនេះនៅបានរៀបចំសកម្មភាពសាកល្បងដាក់សំឡេងឱ្យទស្សនិកជន ដែលបានទាក់ទាញក្រសែភ្នែករបស់អ្នកចូលរួមគ្រប់ៗគ្នា ។

នៅខែតុលា ឆ្នាំ២០១៤ កម្មវិធី "រោងល្ខោនចិន" បានត្រូវបង្កើត និងដំណើរការជាផ្លូវការ ។ ក្នុងរយៈពេលបីឆ្នាំកន្លងទៅនោះ រឿងភាគ "សាមកុក" និងរឿងភាគល្អៗមួយចំនួនទៀតរបស់ប្រទេសចិនបានត្រូវនាំចូល និងចាក់បញ្ចាំងនៅប្រទេសកម្ពុជាតាមរយៈកម្មវិធីនេះ ដែលបានទទួលការពេញនិយមពីសំណាក់ទស្សនិកជនខ្មែរ ៕

**ដោយ ម៉ាវ ភីងហ្វី (ស៊ីនហួ ចិន)**